# ខ្ញុំស្រឡាញ់ក្មេងប្រុសដែលចូលចិត្តនិយាយអ៊ូអែ

អែលឌើរ យូន វ៉ាន ហ្គ័រ
នៃពួក 70 នាក់

*ចូរយើងស្រឡាញ់យុវជនទាំងឡាយរបស់យើង ទោះបីជាពួកគេមួយចំនួន គឺជាក្មេងប្រុសដ៏អូអែក៏ដោយ ។ ចូរយើង បង្រៀនពួកគេឱ្យផ្លាស់ប្ដូរជីវិតរបស់ខ្លួន ។*

ខ្ញុំចង់និយាយប្រាប់អ្នករាល់គ្នាពីយុវជនមួយក្រុមដែលចូលចិត្តនិយាយអ៊ូអែ ដែលខ្ញុំបានជួបនៅពេលខ្ញុំធ្វើជាប៊ីស្សពវ័យក្មេងក្នុងទីក្រុងសេអ៊ូល ប្រទេសកូរ៉េ កាលពីច្រើនឆ្នាំកន្លងមកហើយ ។ យុវជនទាំងនេះរស់នៅជិត គេហដ្ឋានរបស់ខ្ញុំ ។ នៅពេលនោះក្នុងចំណោមពួកគេមានតែម្នាក់ ឬពីរនាក់ប៉ុណ្ណោះ ដែលជាសមាជិកសាសនាចក្រ ។ ក្មេងប្រុសដែលជាសមាជិក គឺជាសមាជិកសាសនាចក្រនេះតែម្នាក់ឯងគត់នៅក្នុងគ្រួសាររបស់ខ្លួន ។ ពួកគេគឺជាមិត្តភក្តិនឹងគ្នា ហើយពួកគេបានមកលេង ហើយជួបជុំនៅឯព្រះវិហារ ។ ពួកគេចូលចិត្តលេងប៉េងប៉ុងនៅក្នុងថ្ងៃធម្មតា ហើយចូលចិត្តមានសកម្មភាពកំសាន្តសប្បាយនៅថ្ងៃសៅរ៍ ។ ពួកគេភាគច្រើនពុំមែនជាសិស្សពូកែនៅក្នុងថ្នាក់នោះឡើយ ហើយមានមនុស្សជាច្រើនបានគិតថា ពួកគេគឺជាមេបង្កបញ្ហាទៀតផង ។

នៅពេលនោះ ខ្ញុំមានកូនប្រុសពីរនាក់ ម្នាក់មានអាយុប្រាំពីរឆ្នាំ ហើយម្នាក់ទៀតមានអាយុប្រាំបួនឆ្នាំ ។ ខ្ញុំមិនបានដឹងថា តើខ្ញុំត្រូវធ្វើអ្វីចំពោះយុវជនទាំងនេះឡើយ ។ ពួកគេគឺជាមនុស្សឆ្គុងឆាំង រហូតមានពេលមួយ ភរិយារបស់ខ្ញុំ ប៊ុនយ៉ាំង បានសួរខ្ញុំថាតើយើងអាចផ្លាស់ទៅវួដមួយទៀតបានដែរឬទេ ដើម្បីឱ្យកូនប្រុសរបស់យើងអាចមើលឃើញ ពីគំរូល្អរបស់យុវជនដទៃទៀត ។ ខ្ញុំបានពិចារណា ហើយបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ដើម្បីជួយខ្ញុំឱ្យស្វែងរកឃើញវិធីជួយដល់យុវជនទាំងនេះ ។ ទីបំផុត ខ្ញុំបានសំរេចចិត្តសាកល្បងបង្រៀនពួកគេពីរបៀបដែលពួកគេ អាចផ្លាស់ប្ដូរ ជីវិតរបស់ខ្លួនបាន ។

មានក្ដីស្រមៃដ៏ជាក់ច្បាស់មួយបានកើតមាននៅក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំបានទទួលអារម្មណ៍ថា បើពួកគេក្លាយខ្លួនទៅជាពួកអ្នកផ្សព្វផ្សាយសាសនា នោះជីវិតរបស់ពួកគេនឹងមានការផ្លាស់ប្ដូរ ។ ចាប់ពីពេលនោះមក ខ្ញុំចាប់ផ្ដើមមានចិត្តរីករាយ ហើយបានព្យាយាមដើម្បីចំណាយពេលឱ្យបានច្រើននៅជាមួយនឹងពួកគេតាមដែលអាចធ្វើទៅបានដោយបង្រៀនពួកគេពីសារៈសំខាន់នៃការបំរើបេសកកម្ម និងពីរបៀបដើម្បីរៀបចំខ្លួនសំរាប់បេសកកម្ម ។

នៅពេលនោះ អែលឌើរ សូ ដែលជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងម្នាក់បានផ្លាស់ប្ដូរមកកាន់វួដរបស់យើង ។ គាត់គឺជា មនុស្សម្នាក់ដែលបានធំដឹងក្ដីឡើងនៅក្នុងសាសនាចក្រ ហើយកាលពីនៅជាយុវជនកាន់បព្វជិតអើរ៉ុនម្នាក់ គាត់បានចូលរួមនៅក្នុងក្រុមចម្រៀងរបស់យុវជនជាមួយនឹងមិត្តភក្តិរបស់គាត់ ។ គាត់បានជួបនឹងក្មេងប្រុសចូលចិត្ត និយាយអ៊ូអែទាំងនោះនៅក្នុងវួដរបស់យើង ។ អែលឌើរ សូ បានបង្រៀនការពិភាក្សារបស់អ្នកផ្សព្វផ្សាយសាសនា ដល់ពួកអ្នកដែលមិនមែនជាសមាជិក ហើយគាត់ក៏បានបង្រៀនពួកគេពីបទចម្រៀងដែលគាត់ធ្លាប់ច្រៀងផងដែរ ។ គាត់បានបំបែកក្មេងប្រុសទាំងនោះជាបីក្រុមដែលក្រុមនិមួយៗមានគ្នាបួននាក់ ហើយបានដាក់ឱ្យពួកគេថា ជាក្រុមចម្រៀង *Hanaro Quartet* មានន័យថា "រួមគ្នាតែមួយ" ។ ពួកគេរីករាយនៅក្នុងការច្រៀងចម្រៀងរួមគ្នា ប៉ុន្ដែយើងត្រូវមានការអត់ធ្មត់ជាច្រើន នៅពេលយើងបានស្ដាប់ការច្រៀងរបស់ពួកគេនោះ ។

គេហដ្ឋានរបស់យើងបានបើកទ្វារចាំទទួលសមាជិក នៅគ្រប់ពេលដែលពួកគេចង់មកលេង។ ក្មេងប្រុសទាំងនេះបានមកលេងគេហដ្ឋានរបស់យើង ភាគច្រើនគឺនៅចុងសប្តាហ៍ និងនៅថ្ងៃចម្លតាម្តងម្កាលដែរ។ យើងបានធ្វើអាហារឱ្យពួកគេបរិភោគ ហើយបានបង្រៀនពួកគេ។ យើងបានបង្រៀនពួកគេពីគោលការណ៍នៃដំណឹងល្អ ក៏ដូចជាការយកដំណឹងល្អទៅអនុវត្តនៅក្នុងជីវិតរបស់ពួកគេផងដែរ។ យើងបានព្យាយាមធ្វើឱ្យពួកគេមានក្តីស្រមៃចំពោះជីវិតនាពេលអនាគតរបស់ខ្លួន។

ពួកគេបានច្រៀងចម្រៀងរួមគ្នា នៅគ្រប់ពេលដែលពួកគេបានមកលេងគេហដ្ឋានរបស់យើង។ សម្លេងព្រួៗរបស់ពួកគេបានធ្វើឱ្យក្រដាសត្រចៀករបស់យើងឡើងហ៊ឹង។ ប៉ុន្តែ យើងតែងតែកោតសរសើរដល់ពួកគេជានិច្ច ពីព្រោះការស្តាប់ពួកគេច្រៀងគឺមានសេចក្តីអំណរជាងមើលឃើញពួកគេជួបបញ្ហាទៅទៀត។

សកម្មភាពទាំងនេះនៅតែបន្ត អស់រយៈពេលជាច្រើនឆ្នាំ។ យុវជនទាំងនេះភាគច្រើនបានធំពេញវ័យនៅក្នុងដំណឹងល្អ ហើយក៏មាន *អព្ភូតហេតុមួយ* បានកើតឡើង។ មួយរយៈក្រោយមក ក្មេងប្រុសដែលពុំមែនជាសមាជិកចំនួន ប្រាំបួននាក់បានទទួលបុណ្យជ្រមុជទឹក។ ពួកគេបានផ្លាស់ប្តូរពីក្មេងប្រុសដែលចូលចិត្តនិយាយអ៊ូអែ មកជា "កងទ័ពកម្លោះដ៏ក្លាហាន"។1

ពួកគេបានបំរើបេសកកម្ម ហើយបានជួបនឹងយុវនារីដ៏ស្រស់ស្អាតនៅក្នុងសាសនាចក្រ ហើយបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ។ ពិតណាស់ ពួកគេម្នាក់ៗមានឧបសគ្គខុសប្លែកពីគ្នា នៅពេលពួកគេបំរើបេសកកម្ម ចូលរៀននៅឯសាលា និងរៀបការ ប៉ុន្តែ ពួកគេនៅតែបន្តស្មោះត្រង់ ពីព្រោះពួកគេចង់គោរពតាមពួកអ្នកដឹកនាំរបស់ខ្លួន និងធ្វើឱ្យព្រះអម្ចាស់សព្វព្រះទ័យ។ ឥឡូវនេះ ពួកគេមានក្រុមគ្រួសារដ៏រីករាយ ដោយមានកូនកើតមកក្នុងសេចក្តីសញ្ញា។

ក្មេងប្រុសទាំងប្រាំបួននាក់ដែលចូលចិត្តនិយាយអ៊ូអែទាំងនោះ រួមទាំងភរិយា និងកូនចៅរបស់ពួកគេផងដែរ បានក្លាយទៅជាសមាជិកដ៏សកម្មចំនួន 45 នាក់នៅក្នុងនគររបស់ព្រះអម្ចាស់។ ឥឡូវនេះ ពួកគេគឺជាអ្នកដឹកនាំនៅក្នុងវួដ និងស្តេករបស់យើង។ មានម្នាក់គឺជាប៊ីស្សព ពីរនាក់ទៀតបំរើនៅក្នុងគណៈប៊ីស្សព ម្នាក់ទៀតបំរើជាទីប្រឹក្សាជាន់ខ្ពស់ ហើយនឹងពីរនាក់ផ្សេងទៀតគឺជាប្រធានយុវជន។ ក៏មានអ្នកធ្វើជាអ្នកដឹកនាំបេសកកម្មប្រចាំវួដ លេខាប្រតិបត្តិ និង គ្រូបង្រៀនថ្នាក់សិក្ខាសាលាផងដែរ។ ពួកគេនៅតែច្រៀងរួមគ្នាជាក្រុម ហើយ *អព្ភូតហេតុផ្សេងទៀត* បានកើតឡើង---គឺពួកគេពិតជាមានសម្លេងពិរោះមែន!

ការណ៍ដែលជួយធ្វើឱ្យយុវជនទាំងនេះប្រែក្លាយដូចជាពួកកូនប្រុសរបស់ហេលេមិនបាន គឺមាននូវគោលការណ៍ដ៏សំខាន់ ចំនួនពីរ។2 ទោះបីជាអ្នកម្តាយរបស់ពួកគេពុំមែនជាសមាជិកសាសនាចក្រ ហើយពុំបានយល់ពីព្រះបន្ទូលនៃព្រះអម្ចាស់ក្តី ក៏ពួកអ្នកដឹកនាំបព្វជិតភាពបានក្លាយទៅជាឪពុករបស់ពួកគេ ហើយភរិយារបស់ពួកអ្នកដឹកនាំ ទាំងឡាយបានក្លាយទៅជាអ្នកម្តាយរបស់ពួកគេដែរ។

ក្មេងប្រុសទាំងប្រាំបួននាក់នេះ ---បានរៀនសូត្រថា ពួកគេនឹងទទួលពរជ័យ បើពួកគេស្តាប់តាមពួកអ្នកដឹកនាំ សាសនាចក្រ ទោះបីជាពួកគេពុំបានយល់ពីហេតុផលជានិច្ចក៏ដោយ---ខ្ញុំបានហៅពួកគេថាជា "ក្មេងប្រុសនៃ ព្រះអម្ចាស់"។ ពួកគេបានក្លាយខ្លួនដូចជាលោកអ័ដាម ជាឪពុកទីមួយរបស់យើង ហើយជាអ្នកដែលត្រូវបានទេវតាសួរ នៅពេលគាត់ថ្វាយការបូជាដល់ព្រះអម្ចាស់ថា

“ហេតុអ្វីបានជាអ្នកថ្វាយយញ្ញបូជាទាំងឡាយដល់ព្រះអម្ចាស់? ហើយ អ័ដាមបានទូលតបទៅលោកថា : ខ្ញុំមិនដឹងទេ លើកលែងតែព្រះអម្ចាស់ទ្រង់បញ្ជាខ្ញុំប៉ុណ្ណោះ” ។3 ពួកគេមានចិត្ត ម៉ឺងម៉ាត់ដើម្បីគោរព និងបំរើដល់ព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់ខ្លួន ។

ពួកគេក៏បានរៀនសូត្រផងដែរថា ការចូលរួមការប្រជុំសាសនាចក្ររបស់ពួកគេ គឺជារឿងដ៏សំខាន់ ។ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន បានមានប្រសាសន៍នៅក្នុងសុន្ទរកថារបស់លោកស្ដីអំពី “‘សិទ្ធិពីកំណើតរបស់យុវវ័យដ៏ថ្លៃថ្នូរ’ ”ថា “ឥឡូវនេះ ខ្ញុំសូមទាញយកចំណាប់អារម្មណ៍របស់អ្នក ឱ្យមករកសារៈសំខាន់នៃការចូលរួមនៅរាល់ការប្រជុំរបស់អ្នកនៅក្នុងព្រះវិហារ ។ ការចូលរួមដ៏ស្មោះត្រង់នៅក្នុងការប្រជុំសាសនាចក្រនាំមកនូវពរជ័យជាច្រើន ដែលអ្នករាល់គ្នា*មិន* អាចទទួលបានតាម វិធីណាផ្សេងទៀតឡើយ” ។4 នៅពេលពួកគេបានចូលរួមនៅក្នុងការប្រជុំសាសនាចក្ររបស់ខ្លួនជាទៀងទាត់ ក្មេងប្រុសទាំងនោះទទួលអារម្មណ៏នៃសេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ហើយបានរៀនសូត្រពីរបៀបដើម្បីយកគោលលទ្ធិ និងគោលការណ៍ទាំងឡាយរបស់សាសនាចក្រមកអនុវត្ត នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។ ពួកគេក៏បានរៀនសូត្រផងដែរ ពីរបៀបចូលរួមចំណែកដោយសេចក្ដីអំណរ និងភាពរីករាយយ៉ាងក្រៃលែងនៅក្នុងការប្រជុំនានា ។

ឥឡូវនេះ យើងមានកូនប្រុសបីនាក់ រួមទាំងកូនប្រុសពៅរបស់យើងផងដែរ បានកើតនៅក្នុងពេលដែលខ្ញុំបំរើជាប៊ីស្សព ។ នៅពេលកូនប្រុសរបស់យើងបានចំរើនវ័យឡើង នោះក្មេងប្រុសទាំងប្រាំបួននាក់នោះបានក្លាយទៅជា ពួកអ្នកដឹកនាំនៅក្នុងវួដ និងស្ដេក ហើយពួកគេបានក្លាយទៅជាគ្រូបង្រៀន និងជាអ្នកដឹកនាំរបស់កូនប្រុសយើង ។ ពួកគេបានបង្រៀន កូនប្រុសរបស់យើង និងក្មេងប្រុសផ្សេងទៀតតាមរបៀបដូចគ្នាដែលខ្ញុំបានបង្រៀនពួកគេ នៅពេលពួកគេនៅក្មេងដែល ចូលចិត្តបង្កបញ្ហានោះ ។ ពួកគេស្រឡាញ់យុវជន *របស់យើង* តាមរបៀបតែមួយដែល *ខ្ញុំ* បានស្រឡាញ់ពួកគេផងដែរ ។ *ក្មេងប្រុសដែលចូលចិត្តនិយាយអ៊ូអែទាំងនេះកាលពីមុន បានក្លាយទៅជាវីរបុរសរបស់កូនចៅយើង*។ កូនប្រុសរបស់យើង ចូលចិត្តធ្វើតាមគំរូដ៏អស្ចារ្យរបស់ពួកគេ ដើម្បីក្លាយខ្លួនទៅជាពួកអ្នកផ្សព្វផ្សាយសាសនាដ៏ឆ្នើម និងការរៀបការជាមួយ នឹងដៃគូដ៏សុចរិតនៅក្នុងព្រះវិហារបរិសុទ្ធ ។

យុវជនទាំងនេះបន្តជះឥទ្ធិពលដល់គ្រួសាររបស់យើង ។ កាលពីពីរខែមុន វួដរបស់យើងមានសកម្មភាពផ្សព្វផ្សាយសាសនា មួយនៅល្ងាចថ្ងៃសៅរ៍ ដោយអញ្ជើញមនុស្សគ្រប់រូប រួមមានទាំងបុគ្គលដែលមានសមាជិកគ្រួសារជាសមាជិកផងដែរ ។ កូនប្រុសពៅរបស់យើង ស៊ុនយុន ទើបតែត្រឡប់មកពីកម្មវិធីបោះជំរំសំរាប់យុវវ័យវិញ នៅពេលរសៀលនាថ្ងៃដដែលនោះ ។ គាត់បាននិយាយថា គាត់នឹងមិនទៅចូលរួមនៅក្នុងកម្មវិធីផ្សព្វផ្សាយសាសនានោះឡើយ ពីព្រោះគ្រួសាររបស់គាត់សុទ្ធតែជាសមាជិក ហើយគាត់អស់កម្លាំងខ្លាំងណាស់ ។ គាត់មិនបានចូលរួមនៅក្នុងកម្មវិធីនោះឡើយ ។ ភរិយារបស់ខ្ញុំបានទូរស័ព្ទហៅគាត់ដើម្បីពន្យល់ថា មនុស្សគ្រប់គ្នាត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងកម្មវិធីនេះ ។ គាត់បាននិយាយថា “កូនដឹងហើយ ប៉ុន្តែថ្ងៃនេះកូនទៅមិនបានទេ” ហើយក៏បានដាក់ទូរស័ព្ទចុះ ។ នៅល្ងាចនោះ បន្ទាប់ពីការប្រជុំនោះចាប់ផ្ដើមបានបន្តិច នោះស៊ុនយុន បានដើរចូលមក ហើយអង្គុយក្បែរម្ដាយខ្លួនដោយ ស្ងៀមស្ងាត់ ។ គាត់បានខ្សឹបប្រាប់ម្ដាយ របស់ខ្លួនថា “បន្ទាប់ពីកូនបានដាក់ទូរស័ព្ទចុះភ្លាម កូនបាននឹកចាំពីការចោទសួរលោកប៉ាថា តើអ្វីទៅដែលធ្វើឱ្យ ក្រុមចម្រៀង Hanero Quartet មានជោគជ័យយ៉ាងធំធេងនៅក្នុងជីវិតរបស់ពួកគេនោះ ។ គាត់បានប្រាប់កូនថា ពួកគេគោរពតាមពាក្យសម្ដីរបស់ពួកអ្នកដឹកនាំសាសនាចក្រ ហើយថាពួកគេបានចូលរួមនៅក្នុងការប្រជុំសាសនាចក្រ ជាទៀងទាត់ទៀតផង ។ នោះគឺជាគន្លឹះដ៏សំខាន់ដែលបានផ្លាស់ប្ដូរជីវិតពួកគេ ហើយបានធ្វើឱ្យពួកគេមានជោគជ័យយ៉ាងធំធេង” ។ កូនប្រុសរបស់ខ្ញុំបានបន្តទៀតថា “រំពេចនោះ ពាក្យសម្ដីរបស់ឪពុកខ្ញុំបានផុសឡើងនៅក្នុងគំនិតរបស់ខ្ញុំ ហើយខ្ញុំបាន

សំរេចចិត្តធ្វើតាមពួកគេ ពីព្រោះខ្ញុំចង់បានគ្រួសារដ៏រីករាយមួយដូចជាគ្រួសាររបស់ពួកគេដែរ និងចង់មានជោគជ័យនៅក្នុងជីវិតរបស់ខ្ញុំ" ។
បងប្អូនប្រុសជាទីស្រឡាញ់ ចូរយើងស្រឡាញ់យុវជនទាំងឡាយរបស់យើង---ទោះបីជាពួកគេមួយចំនួន គឺជាក្មេងប្រុសអ៊ូអែក៏ដោយ ។ ចូរយើងបង្រៀនពួកគេឱ្យផ្លាស់ប្ដូរជីវិតរបស់ខ្លួន ។ "កូនប្រុសរបស់ហេលេមិន" សំរាប់សម័យទំនើបនេះ ពុំមែនកើតចេញពីគ្រួសារដ៏ថ្លៃថ្លារបស់យើងដែលនៅក្នុងសាសនាចក្រតែម្យ៉ាងនោះទេ ប៉ុន្តែ ពួកគេក៏កើតចេញពីយុវជន ដែលផ្លាស់ប្រែចិត្តជឿថ្មី ដែលពុំមានឪពុកម្ដាយជឿដល់ដំណឹងល្អផងដែរ ។ អ្នករាល់គ្នា ព្រមជាមួយនឹងភរិយារបស់អ្នក ផងដែរ ត្រូវធ្វើជា "ឪពុកម្ដាយល្អ" របស់ពួកគេ 5 រហូតដល់ពួកគេក្លាយខ្លួនដូចជា កូនប្រុសរបស់ហេលេមិន ។

ខ្ញុំមានចិត្តត្រេកអរ ហើយរីករាយដោយមើលឃើញភាពដឹកនាំដោយក្ដីស្រឡាញ់ជាបន្តបន្ទាប់របស់អ្នក ចំពោះយុវជន របស់យើង ។ យុវជនទាំងនេះគឺកូនប្រុសរបស់យើងទាំងអស់គ្នា ។ នៅពេលយើងជួយពួកគេ លើកដំកើងពួកគេ និងគាំទ្រពួកគេ នោះយើងនឹងមានអារម្មណ៍ដូចជាយ៉ូហានដែលបាននិយាយថា "គ្មានសេចក្ដីណាដែលនាំឱ្យខ្ញុំអរសប្បាយលើសជាងសេចក្ដីនេះទេ គឺដែលឮនិយាយថា ពួកកូនខ្ញុំកំពុងតែប្រព្រឹត្តតាមសេចក្ដីនោះ" ។ 6

យុវជនទាំងឡាយជាទីស្រឡាញ់ ចូរយើងគោរពតាមពួកអ្នកដឹកនាំនៃសាសនាចក្រនេះ ហើយចូរធ្វើដូចជាលោកអ័ដាម ដែលជាអ្នកពុំបានដឹងពី "ហេតុផល" ជានិច្ចនោះ ប៉ុន្តែមានចិត្តរីករាយនឹងគោរពតាម ។ ហើយសូមចូលរួមការប្រជុំ សាសនាចក្ររបស់អ្នកដោយស្មោះត្រង់ ។ បើអ្នករាល់គ្នាធ្វើបែបនេះ នោះអ្នករាល់គ្នានឹងរៀនពីរបៀបដើម្បីរៀបចំខ្លួន សំរាប់អនាគតរបស់អ្នក ហើយអ្នកនឹងមានជោគជ័យក្នុងជីវិត ។ ចំពោះក្មេងប្រុសដែលបានកើតនៅក្នុងសាសនាចក្រ និងអ្នកដែលបានក្លាយជាសមាជិកសាសនាចក្រផងដែរ *អ្នករាល់គ្នា* គឺជាកងទ័ពរបស់ព្រះអម្ចាស់ ។ អ្នករាល់គ្នានឹងក្លាយ ទៅជាពួកអ្នកផ្សព្វផ្សាយសាសនាដ៏ឆ្នើម និងជាឪពុកដ៏សុចរិតសំរាប់គ្រួសាររបស់អ្នក ។ ព្រះវរបិតាសួគ៌ នឹងប្រទានពរដល់អ្នករាល់គ្នាឱ្យមានគ្រួសារដ៏រីករាយមួយ ។ អ្នករាល់គ្នាមានអនាគតភ្លឺស្វាងនៅក្នុងដំណឹងល្អ ហើយដូចជា កូនប្រុសរបស់ហេលេមិនដែរ នោះអ្នករាល់គ្នានឹងនាំឱ្យយើងទាំងអស់ជួបនូវសេចក្ដីអំណរដ៏នៅអស់កល្បជានិច្ច ។

ខ្ញុំស្រឡាញ់អ្នករាល់គ្នា ហើយខ្ញុំដឹងថា ព្រះវរបិតាសួគ៌របស់យើងស្រឡាញ់យើងទាំងអស់គ្នា ទើបទ្រង់បានបញ្ជូន ព្រះរាជបុត្រាសំណប់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ឱ្យធ្វើជាព្រះអង្គប្រោសលោះរបស់យើង ។ ប្រធាន ថូម៉ាស អេស ម៉នសុន គឺជាព្យាការីដែលនៅរស់ និងជាអ្នកដែលដឹកនាំយើងនៅក្នុងផ្លូវដ៏ត្រឹមត្រូវ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល អាលម៉ា 53:20--22 ។

2. សូមមើល អាលម៉ា 56:10 ។

3. ម៉ូសេ 5:6 ។

4. Ezra T. Benson, “To the ‘Youth of the Noble Birthright’” *Ensign* ខែ ឧសភា ឆ្នាំ 1986 ទំព័រ 44 អក្សរទ្រេតត្រូវបានបន្ថែម ។

5. នីហ្វេទី 1 1:1 ។

6. យ៉ូហានទី 3 1:4 ។